**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**

**លេខ: ១៦៧ អនក្រ.បក**

# អនុក្រឹត្យ
# ស្តីពី
# គ្រូពុទ្ធិកសិក្សានិងមន្ត្រីបំពេញការងារនៅអគ្គាធិការដ្ឋានពុទ្ធិកសិក្សាជាតិ

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១២១៣/១៣៩៣ ចុះថ្ងៃទី២១ ខែធ្នូ ឆ្នាំ២០១៣ ស្តីពីការកែសម្រួលនិងបំពេញបន្ថែមសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៤១៦/៣៦៨ ចុះថ្ងៃទី៤ ខែមេសា ឆ្នាំ២០១៦ ស្តីពីការកែសម្រួលនិងបំពេញបន្ថែមសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ០៦/នស/៩៤ ចុះថ្ងៃទី៣០ ខែតុលា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីសហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១២០១/៤៥០ ចុះថ្ងៃទី១ ខែធ្នូ ឆ្នាំ២០០១ ស្តីពីបៀវត្សមូលដ្ឋាននិងប្រាក់បន្ទាប់បន្សំនៃបៀវត្សរបស់មន្ត្រីរាជការស៊ីវិល
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១០១៤/១១៧៥ ចុះថ្ងៃទី២ ខែតុលា ឆ្នាំ២០១៤ ស្តីពីគោលការណ៍រួមនៃការរៀបចំមុខងារសាធារណៈរបស់រដ្ឋ
- បានឃើញអនុក្រឹត្យលេខ១៥៤ អនក្រ.បក ចុះថ្ងៃទី១១ ខែកក្កដា ឆ្នាំ២០១១ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅរបស់ក្រសួងធម្មការនិងសាសនា
- យោងតាមសំណើរបស់រដ្ឋមន្ត្រីក្រសួងធម្មការនិងសាសនា រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ និងរដ្ឋមន្ត្រីក្រសួងមុខងារសាធារណៈ

## សម្រេច
## ជំពូកទី១
## បទប្បញ្ញត្តិទូទៅ

**មាត្រា១.-**

អនុក្រឹត្យនេះមានគោលបំណងលើកកម្ពស់ប្រសិទ្ធភាពនៃការបំពេញការងាររបស់មន្ត្រីសង្ឃនៅអគ្គាធិការដ្ឋានពុទ្ធិកសិក្សាជាតិនៃក្រសួងធម្មការនិងសាសនា។

**មាត្រា២ .-**

អនុក្រឹត្យនេះមានគោលដៅកំណត់ការរៀបចំផែនការ គោលការណ៍និងលក្ខខណ្ឌនៃការជ្រើសរើស និងបច្ច័យនិច្ចភត្តសម្រាប់សេវាបង្រៀននិងការបំពេញការងាររបស់មន្ត្រីសង្ឃនៅអគ្គាធិការដ្ឋានពុទ្ធិកសិក្សាជាតិនៃក្រសួងធម្មការនិងសាសនា។

**មាត្រា៣ .-**

អនុក្រឹត្យនេះមានវិសាលភាពអនុវត្តចំពោះបេក្ខសមណៈ និង បេក្ខជនដែលប្រឡងជាគ្រូពុទ្ធិកសិក្សា គ្រូពុទ្ធិកសិក្សាជាបព្វជិត ព្រមទាំងមន្ត្រីសង្ឃដែលបំពេញការងារនៅអគ្គាធិការដ្ឋានពុទ្ធិកសិក្សាជាតិនៃក្រសួងធម្មការនិងសាសនា។

## ជំពូកទី២
## ការរៀបចំផែនការគ្រូពុទ្ធិកសិក្សានិងមន្ត្រីបំពេញការងារ នៅអគ្គាធិការដ្ឋានពុទ្ធិកសិក្សាជាតិ

**មាត្រា៤ .-**

អគ្គាធិការដ្ឋានពុទ្ធិកសិក្សាជាតិ ត្រូវរៀបចំផែនការគ្រូពុទ្ធិកសិក្សានិងមន្ត្រីបំពេញការងារដែលរួមមាន គ្រូក្របខណ្ឌពុទ្ធិកសិក្សាជាគ្រហស្ថ គ្រូក្របខណ្ឌពុទ្ធិកសិក្សាជាបព្វជិត គ្រូជាប់កិច្ចសន្យាជាគ្រហស្ថ គ្រូជាប់កិច្ចសន្យាជាបព្វជិត មន្ត្រីរាជការក្របខណ្ឌ និងមន្ត្រីកិច្ចសន្យាបំពេញការងារនៅពុទ្ធិកសិក្សាផ្អែកលើសេចក្តីត្រូវការនៃការបណ្តុះបណ្តាល ប្រភេទមុខតំណែង អង្គភាព និងទីកន្លែងបំពេញការងារ។

សេចក្តីព្រាងផែនការនេះ ត្រូវដាក់ជូនក្រសួងធម្មការនិងសាសនា ដើម្បីពិនិត្យនិងដាក់បញ្ចូលក្នុងផែនការរួមនៃផែនការក្របខណ្ឌមន្ត្រីរាជការនិងមន្ត្រីជាប់កិច្ចសន្យាប្រចាំឆ្នាំតាមនីតិវិធីជាធរមាន។

## ជំពូកទី៣
## គោលការណ៍និងលក្ខខណ្ឌនៃការជ្រើសរើសគ្រូពុទ្ធិកសិក្សា

**មាត្រា៥ .-**

ការប្រឡងជ្រើសរើសគ្រូពុទ្ធិកសិក្សា ត្រូវអនុលោមតាមលក្ខខណ្ឌដូចគ្រូបង្រៀនគ្រប់កម្រិតនៃក្រសួងអប់រំ យុវជន និងកីឡានិងត្រូវអនុវត្តអនុលោមតាមបទប្បញ្ញត្តិនៃច្បាប់ស្តីពីសហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិល និងលិខិតបទដ្ឋានគតិយុត្តជាធរមាន។

អគ្គាធិការដ្ឋានពុទ្ធិកសិក្សាជាតិ អាចកំណត់លក្ខខណ្ឌបន្ថែមនៃការជ្រើសរើសផ្អែកលើសេចក្តីត្រូវការរបស់អគ្គាធិការដ្ឋានពុទ្ធិកសិក្សាជាតិ។

បេក្ខសមណៈនិងបេក្ខជនត្រូវមានអាយុមិនលើស៤៥(សែសិបប្រាំ)ឆ្នាំគិតត្រឹមថ្ងៃប្រឡង។

**មាត្រា៦ .-**

ក្រសួងធម្មការនិងសាសនា ត្រូវចេញប្រកាសទទួលស្គាល់លទ្ធផលនៃការប្រឡងជ្រើសរើសបេក្ខសមណៈ និងបេក្ខជនដែលបានប្រឡងជាប់ស្ថាពរជាគ្រូក្របខណ្ឌពុទ្ធិកសិក្សាតាមនីតិវិធីជាធរមាន។

បេក្ខសមណៈនិងបេក្ខជនដែលប្រឡងជាប់ស្ថាពរជាគ្រូក្របខណ្ឌពុទ្ធិកសិក្សា ត្រូវឆ្លងកាត់វគ្គបណ្តុះបណ្តាលគរុកោសល្យដែលរៀបចំដោយអគ្គាធិការដ្ឋានពុទ្ធិកសិក្សាជាតិ។ រយៈពេលនៃការបណ្តុះបណ្តាលគរុ-កោសល្យ ត្រូវបានចាត់ទុកជារយៈពេលនៃការធ្វើកម្មសិក្សា។ ក្នុងករណីរយៈពេលបណ្តុះបណ្តាលគរុកោសល្យតិចជាង១២(ដប់ពីរ)ខែ គរុសមណសិស្ស-សិស្ស និងគរុសមណនិស្សិត-និស្សិត ត្រូវបំពេញកម្មសិក្សាបន្ថែមឱ្យគ្រប់រយៈពេល១២(ដប់ពីរ)ខែ ទើបអគ្គាធិការដ្ឋានពុទ្ធិកសិក្សាជាតិ ស្នើសុំការតាំងស៊ប់ទៅក្រសួងធម្មការនិងសាសនា អនុលោមតាមបទប្បញ្ញត្តិជាធរមាន។

គរុសមណសិស្ស-និស្សិតដែលលាចាកសិក្ខាបទនឹងត្រូវបានតាំងស៊ប់ក្នុងក្របខណ្ឌមន្ត្រីរាជការស៊ីវិល។

**មាត្រា៧.-**

គុសមណសិស្ស-និស្សិតដែលគង់នៅជាបព្វជិតហើយបំពេញការងារនៅអគ្គាធិការដ្ឋានពុទ្ធិកសិក្សាជាតិឬនៅតាមគ្រឹះស្ថានពុទ្ធិកសិក្សា រាជរដ្ឋាភិបាលរក្សាទុកក្របខណ្ឌ ព្រមទាំងអតីតភាពការងារក្នុងមុខងារសាធារណៈ។

ករណីលាចាកសិក្ខាបទនៅពេលក្រោយ សាមីខ្លួននឹងត្រូវបានបញ្ចូលក្នុងក្របខណ្ឌមន្ត្រីរាជការស៊ីវិលដោយផ្តល់ជូនក្របខណ្ឌ ឋានន្តរស័ក្តិ និងថ្នាក់ដែលរាប់គិតចាប់ពីកាលបរិច្ឆេទនៃការតាំងស៊ប់រហូតដល់ថ្ងៃលាចាកសិក្ខាបទ ដោយមិនរំលឹកបច្ច័យនៃឋានន្តរស័ក្តិនិង/ឬថ្នាក់ឡើយ។ ចំពោះផលប្រយោជន៍នៃការចូលនិវត្តន៍ ត្រូវគិតផ្អែកលើអតីតភាពការងារដែលរាប់គិតចាប់ពីកាលបរិច្ឆេទនៃការដាក់ឱ្យធ្វើកម្មសិក្សារហូតដល់ថ្ងៃចូលនិវត្តន៍ អនុលោមតាមរបបសន្តិសុខសង្គមសម្រាប់មន្ត្រីរាជការស៊ីវិលជាធរមាន។

**មាត្រា៨.-**

អគ្គាធិការដ្ឋានពុទ្ធិកសិក្សាជាតិ ត្រូវកំណត់និយាមនៃការផ្តល់សេវាបង្រៀនចំពោះគ្រូពុទ្ធិកសិក្សានិងគ្រូជាប់កិច្ចសន្យាសម្រាប់កម្រិតពុទ្ធិកសិក្សានីមួយៗ អនុលោមតាមនិយាមដែលកំពុងអនុវត្តក្នុងក្របខណ្ឌនៃក្រសួងអប់រំ យុវជន និងកីឡា។

ក្រសួងធម្មការនិងសាសនា ត្រូវផ្តល់ការគាំទ្រដល់អគ្គាធិការដ្ឋានពុទ្ធិកសិក្សាជាតិ ក្នុងការគ្រប់គ្រងសេវាបង្រៀននៅតាមគ្រឹះស្ថានពុទ្ធិកសិក្សា ដើម្បីធានានូវប្រសិទ្ធភាពនិងគុណភាពនៃការបណ្តុះបណ្តាល។

## ជំពូកទី៤
## បច្ច័យនិច្ចភត្ត

**មាត្រា៩.-**

បច្ច័យនិច្ចភត្ត សំដៅយកប្រាក់ប្រចាំខែជាតម្លៃបច្ច័យដែលត្រូវបានបវារណាសម្រាប់មន្ត្រីសង្ឃបំពេញការងារនៅអគ្គាធិការដ្ឋានពុទ្ធិកសិក្សាជាតិ ដូចខាងក្រោម:

| ល.រ. | បរិយាយ | បច្ច័យនិច្ចភត្ត(រៀល) |
|---|---|---|
| ១ | ព្រះអគ្គាធិការ<br>ព្រះសាកលវិទ្យាធិការ | ១ ៥០០ ០០០ |
| ២ | ព្រះអគ្គាធិការរង<br>ព្រះសាកលវិទ្យាធិការរង | ១ ៤២០ ០០០ |
| ៣ | ប្រធានផ្នែក<br>ព្រឹទ្ធបុរស<br>នាយកពុទ្ធិកមជ្ឈមណ្ឌលគរុកោសល្យ<br>ប្រធានសាខានៃពុទ្ធិកសាកលវិទ្យាល័យ | ១ ៣៩០ ០០០ |
| ៤ | អនុប្រធានផ្នែក<br>ព្រឹទ្ធបុរសរង<br>នាយករងពុទ្ធិកមជ្ឈមណ្ឌលគរុកោសល្យ<br>អនុប្រធានសាខានៃពុទ្ធិកសាកលវិទ្យាល័យ | ១ ៣៧០ ០០០ |

| ល.រ. | បរិយាយ | បច្ច័យនិច្ចកត្ត(រៀល) |
|---|---|---|
| ៥ | ប្រធានការិយាល័យ<br>ប្រធានលេខាធិការដ្ឋាន<br>ប្រធានដេប៉ាតេម៉ងថ្នាក់ឆ្នាំសិក្សាមូលដ្ឋាន<br>ប្រធានបណ្ណាល័យ | ១ ០៨០ ០០០ |
| ៦ | គ្រូក្របខណ្ឌពុទ្ធិកសិក្សាកម្រិតឧត្តម(បង្រៀននៅពុទ្ធិកសាកលវិទ្យាល័យ) | ១ ០៧០ ០០០ |
| ៧ | នាយកពុទ្ធិកមធ្យមសិក្សាទុតិយភូមិ(វិទ្យាល័យ) | ១ ០០០ ០០០ |
| ៨ | នាយករងពុទ្ធិកមធ្យមសិក្សាទុតិយភូមិ(វិទ្យាល័យ) | ៩៨០ ០០០ |
| ៩ | គ្រូក្របខណ្ឌពុទ្ធិកសិក្សាកម្រិតឧត្តម(បង្រៀននៅពុទ្ធិកមធ្យមសិក្សាទុតិយភូមិ) | ៩៧០ ០០០ |
| ១០ | អនុប្រធានការិយាល័យ<br>អនុប្រធានលេខាធិការដ្ឋាន<br>អនុប្រធានដេប៉ាតេម៉ងថ្នាក់ឆ្នាំសិក្សាមូលដ្ឋាន<br>អនុប្រធានបណ្ណាល័យ | ៩១០ ០០០ |
| ១១ | នាយកពុទ្ធិកមធ្យមសិក្សាបឋមភូមិ(អនុវិទ្យាល័យ) | ៩១០ ០០០ |
| ១២ | នាយករងពុទ្ធិកមធ្យមសិក្សាបឋមភូមិ(អនុវិទ្យាល័យ) | ៩០០ ០០០ |
| ១៣ | គ្រូក្របខណ្ឌពុទ្ធិកសិក្សាកម្រិតមូលដ្ឋាន(បង្រៀននៅពុទ្ធិកមធ្យមសិក្សាបឋមភូមិ) | ៨៩០ ០០០ |
| ១៤ | នាយកពុទ្ធិកបឋមសិក្សា | ៨៤០ ០០០ |
| ១៥ | នាយករងពុទ្ធិកបឋមសិក្សា | ៨៣០ ០០០ |
| ១៦ | គ្រូក្របខណ្ឌពុទ្ធិកសិក្សាកម្រិតបឋម(បង្រៀននៅពុទ្ធិកបឋមសិក្សា) | ៨១០ ០០០ |

គរុសមណសិស្ស-និស្សិត ត្រូវបានប្រគេនបច្ច័យនិច្ចកត្តផ្អែកលើកម្រិតនៃប្រភេទក្របខណ្ឌដែលបានប្រឡងជាប់។

បច្ច័យនិច្ចកត្តសម្រាប់មន្ត្រីសង្ឃបំពេញការងារនៅអគ្គាធិការដ្ឋានពុទ្ធិកសិក្សាជាតិដូចមានកំណត់ខាងលើ ត្រូវរៀបចំប្រគេនមន្ត្រីសង្ឃតាមប្រព័ន្ធធនាគារគិតចាប់ពីថ្ងៃទី១ ខែវិច្ឆិកា ឆ្នាំ២០១៦តទៅ ដោយមិនមានអានុភាពអនុវត្តប្រតិសកម្មឡើយ។

ការកែសម្រួលបច្ច័យនិច្ចកត្តសម្រាប់មន្ត្រីសង្ឃបំពេញការងារនៅអគ្គាធិការដ្ឋានពុទ្ធិកសិក្សាជាតិ ត្រូវកំណត់ដោយអនុក្រឹត្យ តាមសំណើរបស់ក្រសួងធម្មការនិងសាសនា បន្ទាប់ពីបានពិគ្រោះយោបល់ជាមួយក្រសួងមុខងារសាធារណៈនិងក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ។

**មាត្រា១០ .-**

ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ក្រសួងធម្មការនិងសាសនា និងក្រសួងមុខងារសាធារណៈ ត្រូវសហការរៀបចំការបើកបច្ច័យនិច្ចកត្តដូចមានចែងក្នុងអនុក្រឹត្យនេះប្រគេនមន្ត្រីសង្ឃតាមប្រព័ន្ធធនាគារឱ្យបានទាន់ពេលវេលាដូចមន្ត្រីរាជការស៊ីវិល។

**មាត្រា១១.-**

មន្ត្រីសង្ឃដែលជាគ្រូក្របខណ្ឌពុទ្ធិកសិក្សាគង់នៅជាបព្វជិតរហូត ប៉ុន្តែមិនអាចបំពេញមុខងារនៅអគ្គាធិការដ្ឋានពុទ្ធិកសិក្សាជាតិឬគ្រឹះស្ថានពុទ្ធិកសិក្សាបន្តទៀតបាន មន្ត្រីសង្ឃអង្គនោះនឹងត្រូវទទួលបានបច្ច័យនិច្ចភត្តផ្អែកលើអតីតភាពនៃការបង្រៀនកន្លងមកដូចខាងក្រោមៈ

- មានអតីតភាពបង្រៀនក្រោម២០(ម្ភៃ)ឆ្នាំ ទទួលបានបច្ច័យនិច្ចភត្តមួយលើកយ៉ាងតិចស្មើនឹងបច្ច័យនិច្ចភត្តចុងក្រោយគុណនឹង៤(បួន)និងមិនឱ្យលើសបច្ច័យនិច្ចភត្តចុងក្រោយគុណនឹង១០(ដប់) ដោយគណនាផ្អែកលើចំនួនឆ្នាំដែលបានបំពេញការងារ
- មានអតីតភាពបង្រៀនចាប់ពី២០(ម្ភៃ)ឆ្នាំ ដល់ក្រោម៣០(សាមសិប)ឆ្នាំ ទទួលបានបច្ច័យនិច្ចភត្តប្រចាំខែស្មើនឹង៦០(ហុកសិប)ភាគរយនៃបច្ច័យនិច្ចភត្តចុងក្រោយដោយគិតបន្ថែមពីរភាគរយក្នុងមួយឆ្នាំសម្រាប់អតីតភាពលើសពី២០(ម្ភៃ)ឆ្នាំ
- មានអតីតភាពបង្រៀនចាប់ពី៣០(សាមសិប)ឆ្នាំឡើងទៅ ទទួលបានបច្ច័យនិច្ចភត្តប្រចាំខែស្មើនឹង៨០(ប៉ែតសិប)ភាគរយនៃបច្ច័យនិច្ចភត្តចុងក្រោយ។

ក្រៅពីបច្ច័យនិច្ចភត្តផ្អែកលើអតីតភាពនៃការបង្រៀន មន្ត្រីសង្ឃខាងលើនឹងត្រូវទទួលបានរបបសន្តិសុខសង្គមផ្សេងទៀតពាក់ព័ន្ធនឹងសុខភាពនិងគ្រោះថ្នាក់ការងារដូចមន្ត្រីរាជការស៊ីវិល។

## ជំពូកទី៥
## បទប្បញ្ញត្តិដោយឡែក

**មាត្រា១២.-**

មន្ត្រីសង្ឃដែលជាគ្រូក្របខណ្ឌពុទ្ធិកសិក្សា ហើយមានមុខតំណែងក្នុងរចនាសម្ព័ន្ធគ្រប់គ្រងនៅអគ្គាធិការដ្ឋានពុទ្ធិកសិក្សាជាតិ ក្នុងករណីលាចាកសិក្ខាបទ ត្រូវរក្សាមុខតំណែងនៅដដែល ដោយរៀបចំបែបបទស្នើសុំតែងតាំងឡើងវិញ លើកលែងមុខតំណែងដែលបម្រុងទុកសម្រាប់តែបព្វជិត។

ព្រះសង្ឃមានមុខតំណែងក្នុងរចនាសម្ព័ន្ធគ្រប់គ្រងនៅអគ្គាធិការដ្ឋានពុទ្ធិកសិក្សាជាតិនៃក្រសួងធម្មការនិងសាសនាដែលមិនមានក្របខណ្ឌ ក្នុងករណីលាចាកសិក្ខាបទ មិនរក្សាបានមុខតំណែងឡើយ។

ការតែងតាំងមុខតំណែងក្នុងរចនាសម្ព័ន្ធគ្រប់គ្រងនៅអគ្គាធិការដ្ឋានពុទ្ធិកសិក្សាជាតិនៃក្រសួងធម្មការនិងសាសនា ត្រូវអនុលោមតាមអនុក្រឹត្យលេខ១១៤ អនក្រ.បក ចុះថ្ងៃទី៧ ខែកញ្ញា ឆ្នាំ២០១៥ ស្តីពីការកំណត់រចនាសម្ព័ន្ធគ្រប់គ្រងនិងមុខតំណែងក្នុងរចនាសម្ព័ន្ធគ្រប់គ្រងនៃក្រសួង ស្ថាប័នថ្នាក់ជាតិនិងថ្នាក់ក្រោមជាតិនិងបទប្បញ្ញត្តិជាធរមាន។

## ជំពូកទី៦
## អន្តរប្បញ្ញត្តិ

**មាត្រា១៣.-**

មន្ត្រីសង្ឃបំពេញកាងារនៅអគ្គាធិការដ្ឋានពុទ្ធិកសិក្សាជាតិនៃក្រសួងធម្មការនិងសាសនាដែលមានក្នុងពេលបច្ចុប្បន្ន ត្រូវរៀបចំគ្រប់គ្រងអនុលោមតាមគោលការណ៍ដែលមានកំណត់ក្នុងអនុក្រឹត្យនេះ។

គរុសមណសិស្ស-និស្សិតដែលបានប្រឡងជាប់ក្របខណ្ឌគ្រូពុទ្ធិកសិក្សាមុនអនុក្រឹត្យនេះចូលជាធរមាន ហើយនៅរក្សាភាពជាបព្វជិត ព្រមទាំងបាននិងកំពុងបង្រៀននៅគ្រឹះស្ថានពុទ្ធិកសិក្សាចាប់ពីកាលបរិច្ឆេទនៃការទទួលស្គាល់ក្របខណ្ឌដោយក្រសួងធម្មការនិងសាសនា នឹងត្រូវផ្តល់អតីតភាពការងារនិងអត្ថប្រយោជន៍ផ្សេងទៀតស្របតាមបទប្បញ្ញត្តិនៃអនុក្រឹត្យនេះ។

ក្រសួងមុខងារសាធារណៈនិងក្រសួងធម្មការនិងសាសនា ត្រូវសហការរៀបចំគ្រប់គ្រងគ្រូក្របខណ្ឌពុទ្ធិកសិក្សាដែលបានប្រឡងជាប់កន្លងមកឱ្យបានរួចរាល់ក្នុងរយៈពេលយ៉ាងយូរ៣(បី)ខែក្រោយអនុក្រឹត្យនេះចូលជាធរមាន។

## ជំពូកទី៧
## អវសានប្បញ្ញត្តិ

**មាត្រា១៤.-**

ឧបសម្ព័ន្ធទី៣នៃអនុក្រឹត្យលេខ១៥៤ អនក្រ.បក ចុះថ្ងៃទី១១ ខែកក្កដា ឆ្នាំ២០១១ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងធម្មការនិងសាសនា និងបទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងអនុក្រឹត្យនេះ ត្រូវទុកជានិរាករណ៍។

**មាត្រា១៥.-**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងមុខងារសាធារណៈ រដ្ឋមន្ត្រីក្រសួងធម្មការនិងសាសនា រដ្ឋមន្ត្រីគ្រប់ក្រសួងនិងប្រធានគ្រប់ស្ថាប័នដែលពាក់ព័ន្ធ ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះ តាមភារកិច្ចរៀងៗខ្លួនចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ០៧ ខែ សីហា ឆ្នាំ២០១៦

**នាយករដ្ឋមន្ត្រី**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

បានយកសេចក្តីគោរពជម្រាបជូន

សម្តេចអគ្គមហាសេនាបតីតេជោនាយករដ្ឋមន្ត្រី សូមហត្ថលេខា

**ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងធម្មការនិងសាសនា**

**ហ៊ឹម ឆែម**

**ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ**

**អូន ព័ន្ធមុនីរ័ត្ន**

**រដ្ឋមន្ត្រីក្រសួងមុខងារសាធារណៈ**

**ពេជ្រ ប៊ុនធិន**

**កន្លែងទទួល:**
- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចអគ្គមហាសេនាបតីតេជោ នាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យសម្តេច ឯកឧត្តម លោកជំទាវឧបនាយករដ្ឋមន្ត្រី
- ដូចមាត្រា១៥
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ